**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

| | |
|---|---|
| **សាលាឧទ្ធរណ៍** | **តាងនាមប្រជារាស្ត្រខ្មែរ** |
| | **សាលាឧទ្ធរណ៍ភ្នំពេញ** |
| សំណុំរឿងរដ្ឋប្បវេណី | បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០១២។ |
| លេខ : ៣៤៦ | |
| ចុះថ្ងៃទី ០២_០៨_២០១១ | |
| សាលដីកា | |
| លេខ : ២២ "ក្រ.ឋ សទ" | |
| ចុះថ្ងៃទី ២៤_០៧_២០១២ | |

## សមាសភាពក្រុមប្រឹក្សា

- ឯកឧត្តម [redacted] ជាប្រធាន
- ឯកឧត្តម [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

## ក្រឡាបញ្ជី

លោក [redacted]

- ដើមចោទគណៈកម្មការវត្តព្រះជីវធំ គណៈកម្មការទ្រទ្រង់សាលារៀនព្រះជីវធំ មានឈ្មោះ [redacted] សុខុម ឈ្មោះ [redacted] សន ឈ្មោះ [redacted] ឡាច ឈ្មោះ [redacted] យូម និងឈ្មោះ [redacted] សារិន ។

មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ។

- ចុងចម្លើយឈ្មោះ [redacted] សាំង ភេទប្រុស ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិកណ្តាល ឃុំកំពង់សឹង ស្រុកព្រះស្តេច ខេត្តព្រៃវែង ។

## ខ្លឹមសារនៃការទាមទារ

ដើមចោទប្តឹងសុំទាមទារដីទំហំ ១២៥៣ម៉ែត្រការ៉េ ពីចុងចម្លើយឈ្មោះ [redacted] សាំង ។

## អង្គហេតុ និង ចំណុចវិវាទ

ភាគីដើមចោទថា ចុងចម្លើយឈ្មោះ [redacted] សាំង បានសុំដីដែលកំពុងមានទំនាស់ពីព្រះចៅអធិការវត្តព្រះនាម [redacted] ថាវ (បច្ចុប្បន្នសុគតហើយ) ដើម្បីធ្វើស្រែចិញ្ចឹមជីវិត ហើយឈ្មោះ [redacted] សាំង នេះបានរំលោភយកដីខាងលើនេះ បំណាងយកធ្វើជាកម្មសិទ្ធិ ។

## ការអះអាងរបស់គូភាគី

## នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

- ដើមចោទឈ្មោះ [redacted] សុខុម ឈ្មោះ [redacted] សន ឈ្មោះ [redacted] ឡាច ឈ្មោះ [redacted] យូម និងឈ្មោះ [redacted] សារិន ។

មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ។

- ចុងចម្លើយឈ្មោះ [redacted] សាំង (វត្តមាន)





Scanned with CamScanner

- លោក [redacted] មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ធ្វើសេចក្តីថ្លែងការណ៍ថា: ដីទំនាស់មានទំហំ ១២៥៣ ម៉ែតការ៉េ ដែលខ្លួនប្តឹងទាមទារពីចុងចម្លើយ ដីនេះជាដីរបស់វត្តតាំងពីមុនម្លេះ វត្តកាន់កាប់ឆ្នាំ១៩៧៩ នៅឆ្នាំ ១៩៩៥-១៩៩៦ ដីនេះមានប្លង់រួចមកហើយ មួយប្លង់ជាកម្មសិទ្ធរបស់វត្ត មួយប្លង់ទៀតកម្មសិទ្ធរបស់សាលារៀន។ លោក[redacted] សាំង បានខ្ចីដីនេះពីលោកតា[redacted] ថាវ អតីតអធិការវត្ត នៅឆ្នាំ១៩៧៩។ ក្រោយមកលោក [redacted] សាំង បានរំលោភយកដីនេះ ទំហំ ១២៥៣ម៉ែតការ៉េវត្តកាន់កាប់តែម្តង ព្រោះដីនេះរដ្ឋបានចុះបញ្ជីត្រឹមត្រូវប្រគល់ឱ្យវត្ត និង សាលារៀនកាន់កាប់។ សូមក្រុមប្រឹក្សាមេត្តាសម្រេចច្រានចោលសាលក្រមលេខ: ១៩ ឃ ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១០ របស់សាលាដំបូងខេត្តព្រៃវែង។

ចុងចម្លើយឈ្មោះ [redacted] សាំង បានថ្លែងហេតុថា: ខ្លួនពុំបានខ្ចីដីពីវត្តទេ គឺខ្លួនបានរស់នៅលើដីនេះតាំងពី ឆ្នាំ១៩៧៩ ម្លេះ ខ្លួនបង្កបង្កើនផលលើដីនេះរហូតមកពុំដែលដាច់។ សំណូមពរ សុំគ្រប់គ្រងដីនេះបន្តទៀត។

<u>សំអាងហេតុ និង សេចក្តីបញ្ចប់</u>

<u>សាលាឧទ្ធរណ៍ យល់ឃើញថា:</u>

១- បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] សន ឈ្មោះ[redacted]ហរិន ឈ្មោះ [redacted] យុម និងឈ្មោះ [redacted] សុខុម ប្តឹងឧទ្ធរណ៍នឹងសាលក្រមរដ្ឋប្បវេណីលេខ ១៩ ឃ ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១០ របស់សាលាដំបូងខេត្តព្រៃវែង ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច បានធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ យោងតាមមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី សាលាឧទ្ធរណ៍ទទួលទាញហេតុផលដោយផ្ទាល់មាត់។

២- តាមការអះអាងរបស់សហដើមចោទថា ដីទំនាស់ទំហំ ១២៥៣ម៉ែត្រការ៉េ ដែលខ្លួនប្តឹងទាមទារពីចុងចម្លើយនេះ ជាដីរបស់សាលារៀនបឋមសិក្សាព្រះជីវ៍ធំ ដែលបំបែកចេញពីប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ព.វ ០០០៨៦០ ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ១៩៩៧ ដែលជាកម្មសិទ្ធិរបស់សាលារៀន តែការអះអាងនេះពុំមានលក្ខណៈត្រឹមត្រូវតាមច្បាប់ឡើយ ពីព្រោះតាមលិខិតលេខ ០៨.២០១២ ចុះថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០១២ របស់ការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលស្រុកព្រះស្តេច និងតាមគំនូសបង្ហាញទីតាំងដីទំនាស់រវាងនាយកសាលារៀនបឋមសិក្សាព្រះជីវ៍ធំ និងឈ្មោះ [redacted] សាំង បង្ហាញថាដីរបស់សាលារៀនបឋមសិក្សាព្រះជីវ៍ធំមានទំហំ ៤៤ ២០៦ ម៉ែត្រការ៉េ ដែលមានក្នុងប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលវត្ថុលេខ Jx1 ០០២២ ចុះថ្ងៃទី ០៩ ខែមករា ឆ្នាំ១៩៩៧។ ឯដីរបស់ឈ្មោះ[redacted]សាំង មានទំហំ ៣៥២៧ ម៉ែត្រការ៉េ ហើយដែលដីនេះ មិនស្ថិតនៅក្នុងប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ Jx1 ០០២២ នេះទេ ហើយក៏ពុំជាន់គ្នាដែរ ព្រមទាំងមានដីបំរុងនៅចន្លោះកណ្តាលទៀតផង។

ម្យ៉ាងទៀត តាមការអះអាងរបស់សហដើមចោទថា ដីទំនាស់នេះ ចុងចម្លើយបានខ្ចីពីលោកតា [redacted] ថាវ អតីតចៅអធិការវត្តតាំងពីឆ្នាំ ១៩៧៩ មកម្លេះ តែចំណុចនេះ ចុងចម្លើយមិនទទួលស្គាល់ឡើយ ដោយបានអះអាងថា ខ្លួនមិនបានខ្ចីដីនេះពីលោកតា [redacted] ថាវ ទេ ហើយក៏ពុំមានឯកសារអ្វីបញ្ជាក់ច្បាស់លាស់ដែរ តែទាំងដើមចោទ និងចុងចម្លើយ បានទទួលស្គាល់ថា ចុងចម្លើយបានចូលកាន់កាប់ដីទំនាស់តាំងពីឆ្នាំ១៩៧៩ មកដល់បច្ចុប្បន្នដែលចំណុច



Scanned with CamScanner

នេះជាភស្តុតាង បង្ហាញឱ្យឃើញនូវនត្ថិភាពនៃបណ្តឹងទាមទាររបស់សហដើមចោទដែលពុំមានមូលដ្ឋានគតិយុត្តឡើយ គប្បីសាលា ឧទ្ធរណ៍ពិចារណាតាមច្បាប់ ។

៣- សាលក្រមរដ្ឋប្បវេណីលេខ ១៩ ឃ ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១០ របស់សាលាដំបូងខេត្តព្រៃវែង ដែលសម្រេចមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ ដែលគប្បីសាលាឧទ្ធរណ៍តម្កល់ទុកជាបានការតាមច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១- ច្រានចោលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] សន ឈ្មោះ [redacted] សារិន ឈ្មោះ [redacted] យូម និងឈ្មោះ [redacted] សុខុម ចោលជាអសារបង់ ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១៩ ឃ ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១០ របស់សាលាដំបូងខេត្តព្រៃវែង ទុកជាបានការ ។

៣- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហដើមចោទ ។

៤- សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០១២ ។

បើកសិទ្ធិប្តឹងសាទុក្ខក្នុងអំឡុងពេល ០១ខែ ចាប់គិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ ។

ក្រឡាបញ្ជី　　ចៅក្រមប្រឹក្សា　　ប្រធានក្រុមប្រឹក្សា

ហត្ថលេខា: [redacted]

---

បានឃើញ
ប្រធានក្រុមប្រឹក្សា

[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី 24 ខែ 7 ឆ្នាំ ២០១២
ក្រឡាបញ្ជី

[redacted]



Scanned with CamScanner